# ខ្លឹមសារសង្ខេបសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង (TC) លើអញ្ញត្រកម្មរបស់អៀង សារី (គោលការណ៍គ្មានការកាត់សេចក្ដីពីរដងចំពោះបទល្មើសតែមួយ) E51/15 ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១

**១.ពាក្យគន្លឹះ៖** ការអនុគ្រោះទោស, ការលើកលែងទោស, ការហាមកាត់សេចក្ដីពីរដង, អាជ្ញាអស់ជំនុំ

**២. នីតិវិធី៖** មេធាវីការពារ **លោក អៀង សារី** អះអាងថា អវតក មិនមានយុត្តាធិការទេ ដោយសារគោលការណ៍គ្មានការកាត់សេចក្ដីពីរដង និង អាជ្ញាអស់ជំនុំ។ ក្នុងករណីបទប្បញ្ញត្តិមិនច្បាស់ គោលការណ៍ចែងក្នុងមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (អាជ្ញាអស់ជំនុំ) គួរត្រូវបកទូលាយគ្រោបទាំងករណីឲ្យជនជាប់ចោទរួចខ្លួន និងករណីជាប់ពិរុទ្ធភាព។ សវនាការឆ្នាំ ១៩៧៩ មិនមែនមានចេតនាឲ្យលោក **អៀង សារី** រួចទោសទេ គឺកាត់ទោស។ ទោះបីមានវិការៈក្នុងសវនាការក្ដី គោលការណ៍គ្មានការកាត់សេចក្ដីពីរដងនៅតែហាមការកាត់ទោសដោយ **អវតក** (កថាខ័ណ្ឌទី១៩ និង ២០)។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញា បានបកស្រាយមាត្រា១២យ៉ាងចង្អៀត ដោយអនុវត្តចំពោះតែករណី ដែលជាជនជាប់ចោទ ត្រូវបានឲ្យរួចខ្លួន។ មាត្រា១៤ នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ ក៏មិនអនុវត្តដែរ (មិនហាមការកាត់សេចក្ដីនៅអវតក) ដោយសារ សាលក្រមរបស់តុលាការឆ្នាំ១៩៧៩ មិនជាស្ថាពរ ម្យ៉ាងទៀតសវនាការនោះ មិនមានភាពយុត្តិធម៌ (កថាខ័ណ្ឌទី២១)។ ជាចុងក្រោយ ដើមបណ្ដឹងរដ្ឋប្បវេណី បានថ្លែងថា សវនាការក្នុងឆ្នាំ ១៩៧៨ មិនត្រូវបានប្រព្រឹត្តឡើង ដោយអនុលោមតាមស្តង់ដាអន្តរជាតិទេ ដូចនេះ សវនាការនោះ មិនអាចរារាំង អវតក មិនឲ្យកាត់សេចក្ដី **លោក អៀង សារី** ជាថ្មីបានទេ (កថាខ័ណ្ឌទី២២)។

## ៣. សំអាងហេតុ និងសេចក្ដីសម្រេច

**ក.** សាលក្រមឆ្នាំ១៩៧៩ មិនមែនជាសាលក្រមតុលាការស្ថាពរទេ អាស្រ័យហេតុនេះ ការអនុគ្រោះទោស (pardon) មិនអនុវត្តបានឡើយ។

**ខ.** ដូចគ្នានេះដែរ គោលការណ៍អាជ្ញាអស់ជំនុំ តាមច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក៏ពុំអាចអនុវត្តបានដែរ ដោយសារ សាលក្រមឆ្នាំ ១៩៧៩ មិនមែនដោះលែងឲ្យរួចខ្លួនទេ (acquittal)។

**គ.** គោលការណ៍ហាមកាត់សេចក្ដីពីរដង អនុវត្តចំពោះតែនីតិវិធីក្នុងស្រុក តែមិនអនុវត្តចំពោះនីតិវិធីមុខតុលាការព្រហ្មទណ្ឌអន្តរជាតិទេ (កថាខ័ណ្ឌទី៣២)។

**៤. កំណត់សំគាល់ (ខ្លឹមសារល្អសម្រាប់ដកស្រង់)**

*អនុលោមតាមគោលការណ៍គ្មានការកាត់សេចក្តី២ដងចំពោះបទល្មើសតែមួយ គ្មានជនណាម្នាក់ត្រូវបាន តុលាការកាត់សេចក្តី២ដងចំពោះបទល្មើសតែមួយឡើយ។ ដោយសារអធិកភាពនៃតុលាការអន្តរជាតិនាពេលបច្ចុប្បន្ន គោលការណ៍នេះ ហាមឃាត់ការកាត់សេចក្តីរបស់តុលាការជាតិនៅពេលបន្ទាប់។ ថ្វីបើដូចនេះក្តី ក៏គោលការណ៍នេះ ពុំគួរហាមឃាត់មិនឲ្យតុលាការអន្តរជាតិ កាត់សេចក្តីលើបទល្មើសតែមួយ នៅពេលបន្ទាប់ ក្នុងកាលៈទេសៈ២ខាងក្រោម៖* ***ក.*** *តុលាការជាតិពុំអនុវត្តតាមលំនាំរបស់ខ្លួន ដូចមានចែងក្នុងលក្ខន្តិកៈ និង* ***ខ.*** *តុលាការជាតិពុំបានធានាទូវ ភាពអនាមិក ឯករាជ្យភាព ឬមធ្យោបាយនៃការវិនិច្ឆ័យសេចក្តីប្រកបដោយប្រសិទ្ធភាព (កថាខ័ណ្ឌទី៣៣)។*

ទស្សនៈទាំងស្រុងសូមមើល៖Trial Chamber ECCC, Decision on IENG Sary's Rule 89 (*Ne Bus in Idem* and Amnesty and Pardon), E51/15, 3 Nov 2011